**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :..........៤.០.........បទ.ប្រក

រាជធានី-ភ្នំពេញ ថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០២

# ប្រ កា ស

## ស្តីអំពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី០៥-០៣-៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីអំពីប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦/អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី១១-១២-៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ

- យោងស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការផែនការ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ នាថ្ងៃទី០៤ ខែមិនា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងបរិក្ខាវិទ្យុគមនាគមន៍ និង ការកែប្រែតម្លៃប្រើប្រាស់រលកអាកាសវិទ្យុ សំរាប់ឆ្នាំ២០០២ ដែលរៀបចំស្នើឡើងដោយក្រុមការងារ តំណាងអង្គភាពជំនាញ ។

## សំរេច

ប្រការ១: កំនត់គោលការប្រើប្រាស់សេវាបរិក្ខាវិទ្យុគមនាគមន៍ ដូចមានឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៣ភ្ជាប់នឹង សេចក្តីប្រកាសនេះ ។

ប្រការ២: ប្រកាសស្តីអំពីការគ្រប់គ្រងបរិក្ខាវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ លេខ០៨១ បទ.ប្រក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១ និងរួមទាំងប្រកាសទាំងឡាយណាដែលមានពីមុន ហើយមានន័យផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៣: ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទក្រសួងប.ទ ត្រូវទទួលបន្ទុកអនុវត្តតាមតួនាទី ភារកិច្ចនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់។

ប្រការ៤: ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រដ្ឋមន្ត្រី

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាពត៌មាន"
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ